Institut Pasteur du Cambodge

រៀបរៀងដោយ វេជ្ជ.ហោង ណៃឃីម / វេជ្ជ.ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥

# វ៉ាក់សាំងបង្ការជំងឺ រលាកថ្លើម ប្រភេទបេ

# (Hepatitis B)

## ១- តើជំងឺរលាកថ្លើមប្រភេទបេជាអ្វី?

ជំងឺរលាកថ្លើមប្រភេទបេ គឺជាជំងឺថ្លើមធ្ងន់ធ្ងរមួយ បង្កដោយមេរោគរលាកថ្លើម ប្រភេទបេ។ ជំងឺរលាកថ្លើម ប្រភេទបេ អាចបណ្តាលអោយ៖

**- រលាកថ្លើមស្រួចស្រាវ**

ករណីបែបនេះ អ្នកជំងឺអាចមានសញ្ញា៖

- រាគ និង ក្អួត
- មិនឃ្លានអាហារ
- ហេវហត់
- ស្បែកឡើងលឿង
- ឈឺតាមសាច់ដុំ សន្លាក់ឆ្អឹង និង ឈឺក្នុងពោះ

**- រលាកថ្លើមរ៉ាំរ៉ៃ**

ក្រោយមានការបង្ករោគ ដោយមេរោគរលាកថ្លើម ប្រភេទបេ អ្នកជំងឺមួយចំនួនបានវិវត្តន៍ទៅជាអ្នកជំងឺរលាកថ្លើមរ៉ាំរ៉ៃ។ ក្នុងទំរង់រលាកថ្លើមរ៉ាំរ៉ៃនេះភាគច្រើន អ្នកជំងឺពុំមានចេញជារោគសញ្ញាអ្វីឡើយ ប៉ុន្តែការបង្ករោគនេះនៅតែអាចវិវត្តន៍យ៉ាងខ្លាំងក្លា ដែលអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរ ដូចជា៖ ក្រិនថ្លើម មហារីកថ្លើម និងស្លាប់បាត់បង់ជីវិត។

គេសង្កេតឃើញថា ការវិវត្តន៍ទៅជាទំរង់រលាកថ្លើម ប្រភេទបេ រ៉ាំរ៉ៃ ភាគច្រើន កើតមានលើកុមារតូចៗ ច្រើនជាងមនុស្សពេញវ័យ។ អ្នកជំងឺរលាកថ្លើមរ៉ាំរ៉ៃអាចចំលងមេរោគទៅអ្នកដទៃទៀតបាន បើទោះបីជាអ្នកជំងឺមិនមានរោគសញ្ញាអ្វីក៏ដោយ។

មនុស្សអាចឆ្លងមេរោគថ្លើម ប្រភេទបេ នេះតាមរយៈ៖

- ឈាម រឺ សារធាតុរាវនៃអ្នកជំងឺបានប៉ះដោយផ្ទាល់មកលើស្បែកដែលមានរបួស
- មុតម្ជុល រឺ វត្ថុមុតស្រួចដែលមានជាប់មេរោគ
- រួមភេទជាមួយអ្នកផ្ទុកមេរោគដោយមិនការពារ
- ប្រើប្រាស់ម្ជុលរួមគ្នា (ចាក់គ្រឿងញៀន)
- ប្រើប្រាស់សំភារៈដែលប្រលាក់ដោយឈាម រឺ សារធាតុរាវនៃអ្នកជំងឺ (កាំបិតកោរ ច្រាសដុសធ្មេញ) (មេរោគនេះអាចរស់នៅបាន ៧ ថ្ងៃ ក្នុងបរិយាកាស)។

ម្តាយដែលមានជំងឺរលាកថ្លើម ប្រភេទបេ អាចចំលងទៅទារកនៅពេលសំរាល។

## ២- វ៉ាក់សាំងបង្ការជំងឺរលាកថ្លើម ប្រភេទបេ

វ៉ាក់សាំងបង្ការជំងឺរលាកថ្លើម ប្រភេទបេ អាចការពារការឆ្លងរាលដាលនៃជំងឺនេះ និងការពារផលវិបាកធ្ងន់ធ្ងរដូចជា ក្រិនថ្លើម និងមហារីកថ្លើមជាដើម។ វ៉ាក់សាំងនេះត្រូវបានណែនាំអោយចាក់ចំនួន ៣ ដូស៖

ដូសទី១: ក្រោយពេលពិនិត្យឈាម បញ្ជាក់ថាគ្មានផ្ទុកមេរោគនេះ ហើយពុំទាន់មានប្រព័ន្ធការពារ

ដូសទី២: ១ ទៅ ២ ខែ បន្ទាប់ពីដូស ទី១

ដូសទី៣: ៦ ទៅ ១៨ ខែ បន្ទាប់ពីដូស ទី២

ចំពោះកុមារតូចៗ ក្នុងករណី ដែលភាពប្រឈម នឹងការឆ្លង មានអាត្រាខ្ពស់ គេអាចនឹងផ្តល់ដូសទី៤បន្ថែម ដោយពុំមានផលប៉ះពាល់អ្វីឡើយ។

## ៣- តើអ្នកណាខ្លះ ដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- អ្នកដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរជាមួយវ៉ាក់សាំងប្រភេទនេះពីមុន ឬ ធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតដែលមាននៅក្នុងវ៉ាក់សាំង
- ចំពោះអ្នកមានជំងឺកំរិតមធ្យម រឺ ធ្ងន់ធ្ងរ ការផ្តល់វ៉ាក់សាំងនេះគួរត្រូវបានពន្យាររហូតដល់ពេលជាសះស្បើយពីជំងឺជាមុនសិន។

## ៤- ផលវិបាកដែលអាចកើតមានក្រោយពេលចាក់វ៉ាក់សាំងនេះ

ក៏ដូចជាឱសថផ្សេងៗទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរដូចជា ប្រតិកម្ម អាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល
- ឡើងកន្ទួលក្រហមលើស្បែក
- ប្រតិកម្មធ្ងន់ធ្ងរ (កម្រមានណាស់)

**ប្រសិនបើមានសញ្ញាប្រតកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**